ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០៤៧/២១

# របាយការណ៍ខែមករា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែកុម្ភៈ ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| | ការផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ៩.៧៧៥ | ៥៤៤.៣៤១ | ២៤៦.៣៨៤ |
| ២ | អង្គការដៃគូ | ០២ | ២.៧៤១ | ១.២៨៩ |
| | សរុប | ៩.៧៧៧ លើក | ៥៤៧.០៨២ នាក់ | ២៤៧.៦៧៣ នាក់ |

##### ខ.១.២. ការផ្សព្វផ្សាយដោយផ្ទាល់តាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

នៅក្នុងខែមករា ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៩.៧៧៥លើក មានអ្នកចូលរួមសរុបចំនួន ៥៤៤.៣៤១នាក់ (ធៀបនឹងខែធ្នូ ឆ្នាំ២០២០ មានចំនួន ៣៨៤.៥៩៤នាក់

គឺមានការកើនឡើងចំនួន ១៥៩.៧៤៧នាក់ ស្មើនឹង ២៩,៣៤% ក្នុងនោះស្ត្រីចំនួន ២៤៦.៣៨៤នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣៧ | ៤.២១៣ | ២.២៥៩ | ២៣ | ៩៨២ | ៤០៦ |
| | សរុប ក្រសួង ស្ថាប័ន | ៣៧ លើក | ៤.២១៣ នាក់ | ២.២៥៩ នាក់ | ២៣ លើក | ៩៨២ នាក់ | ៤០៦ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៥៣២ | ១៧.២០៤ | ៩.១២០ | ៨៥៣ | ៥៦.៦០៤ | ២៧.៨៧៧ |
| ៣ | ខេត្តបាត់ដំបង | ៦៥០ | ២១.១១៨ | ១១.២៦០ | ៤៧៣ | ១៣.០៣០ | ៦.៨០៩ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៣៣ | ១៨.៧៤២ | ១០.២៨៥ | ១០៣ | ៣.៧៨៨ | ១.៦៥៧ |
| ៥ | ខេត្តសៀមរាប | ៣៥៣ | ១២.៨៩២ | ៧.៨១៨ | ៩៨ | ២.៣៥៤ | ១.២៤៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.១៧៦ | ៣៣.៣៧៦ | ១៨.២១៨ | ៧០២ | ១៦.៨៩៧ | ៧.៤៣៤ |
| ៧ | ខេត្តកំពង់ចាម | ២.៤២៤ | ១៣៦.៦៨៨ | ៧៧.៨៤២ | ១.៣០០ | ១៥៤.២២១ | ៣៦.៤៦៦ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៨១ | ២៤.១០០ | ១២.៦៦០ | ១១០ | ៤.៥៣៣ | ២.៥២៨ |
| ១០ | ខេត្តស្វាយរៀង | ៣២៨ | ៩.៩៩១ | ៥.៧៦៩ | | | |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | | | | ៥១ | ៨៧៣ | ៤៤៣ |
| ១៣ | ខេត្តកំពត | ២៨ | ២៨៩ | ១៧៩ | ៤៥ | ៩៦៣ | ៦៤០ |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ៥២ | ៤.០១៦ | ២.២១៣ | | | |
| ១៧ | ខេត្តកែប | ៥ | ៣.៣៨២ | ១.៧៣៤ | ៨ | ៣០៨ | ១៣២ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ១ | ១.៨៧៦ | ១.០៨៥ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៩ | ១.៩០១ | ៣០១ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៥.៩៧២ លើក | ២៨៥.៥៧២ នាក់ | ១៥៨.៤៨៤ នាក់ | ៣.៧៤៣ លើក | ២៥៣.៥៧១ នាក់ | ៨៥.២៣៥ នាក់ |

| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៩.៧៧៥ លើក | ចំនួនមនុស្ស ៥៤៤.៣៤១ នាក់ | ចំនួនស្ត្រី ២៤៦.៣៨៤ នាក់ |
|---|---|---|---|

### ១.១.៣. អង្គការដៃគូ

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្រី |
|---|---|---|---|---|
| សាម៉ារីតាន់ភឺស តំណក់ទឹក គ្រួសារថ្មី និងភឿន (ខេត្តបន្ទាយមានជ័យ) | ផ្សព្វផ្សាយ អប់រំ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ពលករ | ០១ | ២.៥៥៧ | ១.២០៨ |
| | ចែកលេខទូរស័ព្ទមជ្ឈមណ្ឌលព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព និងខិត្តប័ណ្ណដល់ពលករត្រឡប់មកពីប្រទេសថៃ និងប្រទេសម៉ាឡេស៊ី | ០១ | ១៨៤ | ៨១ |
| សរុប | | ០២ លើក | ២.៧៤១ នាក់ | ១.២៨៩ នាក់ |

### ខ.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| សកម្មភាព | លទ្ធផល |
|---|---|
| ខេត្តសៀមរាបៈ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM១០៣MHz និងទូរទស្សន៍ខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស។ | តាមវិទ្យុ ១០៨ លើក (ផ្សាយផ្ទាល់ ៥៤ លើក និងចាក់ផ្សាយឡើងវិញ ៥៤លើក) |
| ខេត្តមណ្ឌលគិរីៈ មន្ទីរធម្មការ និងសាសនាខេត្ត បានធ្វើការផ្សព្វផ្សាយបញ្ជ្រាប តាមវិទ្យុ FM៩៧MHz ក្នុងកម្មវិធី ព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម ចំនួន ២០ថ្ងៃក្នុង១ខែ។ | តាមវិទ្យុ ២០ លើក |
| សរុប | តាមវិទ្យុ ១២៨ លើក |

### ខ.១.៧. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

| សកម្មភាព | ចំនួនលើក |
|---|---|
| - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាៈ ចូលរួមជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC នៅភ្នំពេញ។ | ០១លើក |
| - ខេត្តកំពង់ចាមៈ ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ស្តីពីដំណើរការគ្រប់គ្រងស្ថិតិពលករចំណាកស្រុក និងស្តីពីការរាយការណ៍ករណីរំលោភសេពសន្ថវៈ។ | ០៣លើក |
| - ខេត្តសៀមរាបៈ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុ។ | ០២លើក |
| សរុប | ០៦លើក |

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍)

បានបូកសរុបទិន្នន័យពលករកម្ពុជា ដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេស ក្នុងអំឡុងពេលនៃការរីករាលដាលជម្ងឺកូវីដ-១៩ ប្រចាំថ្ងៃទាំង២៥ រាជធានី-ខេត្ត គិតចាប់ពីថ្ងៃទី០១ ដល់៣១ ខែមករា ឆ្នាំ២០២១ មានចំនួន ៧.៩១៨នាក់ ស្រីចំនួន ៣.៣៦៩នាក់។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១០៧.៩៤៥**នាក់ លើ **១០១.០៥៨**នាក់(ស្រី ៤៦.៩៧២នាក់) អនីតិជន២.៤៧០នាក់។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារ ព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ៣៦០លើក ហើយបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ៤២នាក់(ស្រី១៦នាក់) បានធ្វើការអប់រំ និងឱ្យត្រឡប់ទៅផ្ទះវិញ។

**ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ព្រៃវែង ស្ទឹងត្រែង និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **១២០**លើក។
- ស្នងការដ្ឋាននគរបាលខេត្តកែប មណ្ឌលគិរី និងខេត្តក្រចេះ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារម៉ាស្សា ចំនួន ៨៩គោលដៅ មនុស្សចូលរួម ៣៦១នាក់ ស្រី ២៤៨នាក់។

**ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៦២គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរដែលរៀបការរួច ទៅរស់នៅក្រៅប្រទេស ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាម៉ីខ្លួនបានចំនួន ០៤នាក់ ប្រទេសកូរ៉េ (រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តត្បូងឃ្មុំ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះអប់រំ ធ្វើកិច្ចសន្យា និងដាក់ស្លាកសញ្ញាហាមកុមារចូលបរិវេណឡដុត ជាមួយម្ចាស់សិប្បកម្ម ចំនួន ០២លើក បាន ២៣សិប្បកម្ម។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី (ធៀបនឹងខែធ្នូ ឆ្នាំ២០២០ មានចំនួន ១១ករណី កើនឡើងចំនួន ០៤ករណី)ស្មើនឹង ៣៦,៣៦% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៥នាក់(អនីតិជន ០២នាក់ ជនបរទេស ០១នាក់(វៀតណាម))។

សង្គ្រោះជនរងគ្រោះ ចំនួន ២៤នាក់ មាន: អាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ១០នាក់ និងអាយុពី១៨ឆ្នាំឡើង ០៣នាក់ (ប្រគល់ឱ្យគ្រួសារ ២៤នាក់) ក្នុងនោះមានចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី/០៣ករណី (ថយ ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០១នាក់ អាយុ១៨ឆ្នាំ (ប្រគល់ឱ្យគ្រួសារ)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០១ | ០២ |
| *សរុប* | *០២ ករណី* | *០១ នាក់* | *០២ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៣ករណី/០៨ករណី (កើន ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២៣នាក់ មាន: អាយុក្រោម១៥ឆ្នាំ ១១នាក់ អាយុ១៥-១៧ឆ្នាំ ១០នាក់ និងអាយុពី១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យគ្រួសារ)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ១២ | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៨ | ០៨ | ០៨ |
| -អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ |
| *សរុប* | *១៣ នាក់* | *២៣ នាក់* | *១៣ នាក់* |

## **ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ**

### **ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ**

**ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

  ស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៣ បានទទួល និងសម្ភាសពលករខ្មែរ និងជនទេសន្តរប្រវេសន៍ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម ចំនួន ២០លើក មនុស្សចំនួន ៣៦៦នាក់(ស្រី ១១០នាក់ អនីតិជន ១៩នាក់) ក្នុងនោះមាន៖

  - ខេត្តបន្ទាយមានជ័យ (ប្រចាំខែមករា) មនុស្សចំនួន៥.៨៨៤នាក់ (ស្រី២.៣៨៩នាក់) អនីតិជនចំនួន ៤៥០នាក់។
  - ខេត្តកោះកុង ចំនួន ០៦លើក មនុស្សចំនួន ២៦នាក់ (ស្រី ០៤នាក់)។
  - ខេត្តស្វាយរៀង ចំនួន ០១លើក មនុស្សចំនួន ០៣នាក់ (ស្រី ០៣នាក់)។

# **III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល**

## **ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា**

### **ក.១. ការងារបណ្តុះបណ្តាល**

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហគ្រាសចំនួន ០៤ បើកវគ្គបណ្តុះបណ្តាល ស្តីពីបំណិនជីវិត និងច្បាប់ស្តីពីការងារ សុខភាព សុវត្ថិភាព និងការជួយសង្គ្រោះ។ | ០១ | ៣៤៣ | ៥១ |
| **ខេត្តកំពង់ចាម៖** គ.ខ.ប.ជ ស្រុកចំការលើ បើកវគ្គបណ្តុះបណ្តាលលើកកម្ពស់ កិច្ចការពារសិទ្ធិការងារ សម្រាប់ពលករចំណាកស្រុកដែលមានជំនាញទាបទៅប្រទេសថៃ។ | ០១ | ១៨ | ១២ |
| **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងអង្គការជីវិតនៅកម្ពុជា បើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងកិច្ចការពារកុមារ ដល់មន្ត្រីនគរបាល និងអាវុធហត្ថ នៅស្រុកសូទ្រនិគម ស្វាយលើ ជីក្រែង បន្ទាយស្រី ប្រាសាទបាគង និងក្រុងសៀមរាប។ | ០៤ | ៣៣៣ | ១៤ |
| សរុប | **០៦** វគ្គ | **៦៩៤** នាក់ | **៧៧** នាក់ |

## ក.២. សិក្ខាសាលា

### ក.២.១.សិក្ខាសាលាក្នុងប្រទេស

| សកម្មភាពរៀបចំសិក្ខាសាលា | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍(MGI) របស់កម្ពុជា និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់(GCM) នៅសណ្ឋាគារ Raffles ភ្នំពេញ។ | ០១ | ៣៨ | ១២ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** សហការជាមួយអង្គការ IOM រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើ សៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ | ០១ | ២៧ | ១៣ |
| **រាជធានីភ្នំពេញ៖** អង្គការជំហ៊ានដំបូងកម្ពុជា រៀបចំសិក្ខាសាលា "ស្តីពីការស្វែងយល់ និងការរាយការណ៍ពីការរំលោភបំពានផ្លូវភេទលើកុមារ" នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។ | ០១ | ៤៣ | ១៧ |
| **ខេត្តកំពង់ស្ពឺ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការឃែរកម្ពុជាអន្តរជាតិ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ២០២០ នៃគម្រោងចំណាកស្រុក ដោយសុវត្ថិភាព ក្រោមអធិបតីភាព លោកជំទាវឧ.ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ | ០១ | ៥០ | ៣៥ |
| **ខេត្តព្រះសីហនុ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការឃែរកម្ពុជាអន្តរជាតិ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ២០២០ នៃគម្រោងចំណាកស្រុកដោយសុវត្ថិភាព ក្រោមអធិបតីភាព លោកជំទាវឧ.ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ | ០១ | ៤០ | ២៨ |
| សរុប | **០៥** វគ្គ | **១៩៨** នាក់ | **១០៥** នាក់ |

## ៦. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ៦.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ ៖
    - កិច្ចប្រជុំពិភាក្សាទ្វេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ "ដែលកិច្ចប្រជុំបានពិភាក្សាលើចំណុចដែលនៅសេសសល់ក្នុងសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ" នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម ២៩នាក់(ស្រី ០៦នាក់)។
    - កិច្ចប្រជុំពិភាក្សា SOP ទ្វេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ "ស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" នៅសណ្ឋាគារកាំប៉ូឌីយ៉ាណា អ្នកចូលរួមចំនួន ៣២នាក់(ស្រី ០៨នាក់)។
    - កិច្ចប្រជុំពិភាក្សា កែសម្រួលជាភាសាបរទេស លើគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ជាមួយលោកស្រី **គ្រីស្ទីន ផាកូ** ប្រធានអង្គការអោយអូអឹម IOM នៅសាលប្រជុំ គ.ជ.ប.ជ ។
- **ក្រសួងអប់រំ យុវជន និងកីឡា** សហការជាមួយ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖**
    - បានប្រជុំពិភាក្សារៀបចំសមាសភាពក្រុមការងារ និងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលសៀវភៅ **ការអប់រំ ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** ជាមួយនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា វគ្គមានចូលរួមចំនួន ១២នាក់(ស្រី ០១នាក់)។
    - បានប្រជុំពិភាក្សា ស្តីពីការរៀបចំឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីបង្រៀនបន្តដល់គរុសិស្ស សម្រាប់បង្រៀនសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ លើសៀវភៅ **ការអប់រំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលាគរុកោសល្យខេត្តកំពង់ចាម វគ្គមានចូលរួមចំនួន ១៦នាក់(ស្រី ០៣នាក់)។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖
    - ដឹកនាំនិងបើកកិច្ចប្រជុំត្រួតពិនិត្យ កែសម្រួលខ្លឹមសារ SOP រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ជាភាសាខ្មែរ ដោយមានការចូលរួមពី ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។
- **ខេត្តព្រៃវែង៖** បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះ ជំនួស ដើម្បីជៀសផុតពីការជួញដូរមនុស្ស និងល្បិចកលជនល្មើស ដែលមានអ្នកចូលរួម ៨៤នាក់ ស្រី១០នាក់។

### ៦.២. ការជំនួបពិភាក្សាការងារ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជំនួបពិភាក្សាការងារ ជាមួយលេខាទូត រួមនិងក្រុមការងារ ដែលទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ស្តីពីលទ្ធផលសកម្មភាពការងារនានា មានកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ ការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស ការពង្រឹងការអនុវត្តច្បាប់

និងកិច្ចការយុត្តិធម៌ ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួង-ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍសម្រេចបានកន្លងមក ជាពិសេសការផ្តល់កិច្ចការពារ និងសេវាគាំទ្រជូនជនរងគ្រោះដោយអំពើជួញដូរ និងពលករចំណាកស្រុកដែលវិលត្រលប់ ក្នុងតំណាក់កាលការរីករាលដាលជំងឺកូវីដ-១៩ ។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ ៦៧លើក មានអ្នកចូលរួមសរុប ៨៧៨នាក់ (ស្រី ៤៩០នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៣៣លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៨លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២៦លើក។ (ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយ

អ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកុម្ភៈ ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** **នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃពុធ..១១រោច..ខែ.ចេត្រ.ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី.៧...ខែ.មេសា..ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ~ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៧លើក) មនុស្សចំនួន ៨៧៨នាក់ (ស្រី ៤៩០នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ បានអញ្ជើញជាអធិបតីក្នុង៖<br>- កិច្ចប្រជុំពិភាក្សាអំពី "វឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងដំណោះស្រាយ" ជាមួយឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ វត្តមានចូលរួមចំនួន ៣៣នាក់ ស្រី ១២នាក់។<br>- កិច្ចប្រជុំ របាយការណ៍ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១" នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន ១០៥នាក់ ស្រី ៥៩នាក់។<br>- ពិធីសម្ពោធការចាប់ផ្តើមអនុវត្តន៍គម្រោងបញ្ចប់អំពើហឹង្សាលើកុមារនៅក្នុង និងជុំវិញសាលារៀន "End Violence Against Children Project ( EDN VAC ) in and around school " នៅសណ្ឋាគារសាន់វ៉េ ភ្នំពេញ ដោយមានការរៀបចំសម្របសម្រួលអង្គការ Save the Children ដែលមានអ្នកចូលរួមសរុប៥០នាក់ ។<br>- កិច្ចប្រជុំត្រួតពិនិត្យ កែសម្រួលទៅលើសេចក្តីព្រាង គោលនយោបាយជាតិស្តីពី សុខភាពជនទេសន្តរប្រវេសន៍ នៅសាលប្រជុំគ.ជ.ប.ជ។<br>- បានដឹកនាំក្រុមការងារគ.ជ.ប.ជ លោកស្រីអភិបាលរងខេត្តសៀមរាម រួមនិងប្រធានអង្គការអាយអូអឹម អង្គការWHO អង្គការយូនីសេហ្វ អង្គការយូអិនអេហ្វភីអេ អង្គការជីភីអូ មន្ត្រីគម្រោង RCO បានចុះតាមដាន ត្រួតពិនិត្យការអនុវត្តផែនការគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងតំណាក់កាលកូវីដ១៩- នៅសាលាស្រុកក្រឡាញ់ ខេត្តសៀមរាប។<br>- បានដឹកនាំក្រុមការងារ និងអង្គការដៃគូអភិវឌ្ឍ បានចុះសាកសួរ និងសំណេះសំណាលផ្ទាល់ជាមួយ និងប្រជាពលរដ្ឋ ដែលជាពលករទេសន្តរប្រវេសន៍ទើបវិលត្រលប់ពីក្រៅប្រទេស ស្ថិតក្នុងភូមិល្បើក ឃុំដូនកែវ ស្រុកពួក និងភូមិ-ឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប និងបានចុះទស្សនកិច្ច ពិនិត្យផ្ទាល់ទៅដល់ទីកន្លែងសួនច្បារដំណាំ និងរោងចិញ្ចឹមសត្វ ដែលពួកគាត់ទទួលបានពីការឧបត្ថម្ភគាំទ្រ ពីគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំកែសម្រួលសេចក្តីព្រាងចុងក្រោយ ស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ កម្ពុជា-ថៃ "Pending points from the bilateral meeting" ជាមួយតំណាងអង្គការ IOM ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅប្រជុំគ.ជ.ប.ជ។ |

- កិច្ចប្រជុំពិភាក្សាលើចំណុចសេសសល់ទ្វេភាគីកម្ពុជា-ថៃ អំពីសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ SOP ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម ២៩នាក់ ស្រី០៦នាក់។
- ប្រជុំតាមវីដេអូរ (Conference Video) រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ស្តីពី "ស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អ្នកចូលរួមចំនួន ៣២នាក់ ស្រី ០៨នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ ។
- ដឹកនាំក្រុមការងារដើម្បីយកខ្លឹមសារ នីតិវិធីស្តង់ដារប្រតិបត្តិ SOP ស្តីពីនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ដើម្បីសុំការសម្របសម្រួលចង្អុលបង្ហាញ និងកែសម្រួលភាសាខ្មែរមួយចំនួនពី ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។
- នៅសាលាឃុំចាន់ស មានកិច្ចប្រជុំរវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ លោកជំទាវ **យូ សុភា** អភិបាលរងខេត្តសៀមរាប ប្រធានអង្គការ IOM ប្រចាំប្រទេសកម្ពុជា ប្រធានអង្គការយូនីសេហ្វ UNICEF អង្គការដៃគូអភិវឌ្ឍមាន តំណាងអង្គការយូអិនអេហ្វ ភីអេ UNFPA ជាមួយនឹងមន្ត្រីអភិបាលស្រុក ឃុំ សង្កាត់ និងមេភូមិ បងប្អូនប្រជាពលរដ្ឋ និងបងប្អូនដែលទើបវិលត្រលប់ពីក្រៅប្រទេស គោលបំណង ដើម្បីតាមដានត្រួតពិនិត្យ និងសិក្សាស្វែងយល់ពីគម្រោងអនុវត្តរួមគ្នារវាងរាជរដ្ឋាភិបាល និងយូអិន នៅក្នុងរដ្ឋបាលស្រុក ឃុំ និងអង្គការដៃគូរអភិវឌ្ឍ នៅក្នុងឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ០៧ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៥ច្បាប់ លិខិតចូល ២៣ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមករា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ខែមករា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**

- ឯកឧត្តម អគ្គលេខាធិការរង៖ ដើម្បីបង្រៀនបន្តដល់គរុសិស្ស សិស្ស

  ○ បានដឹកនាំក្រុមការងារ ចូលរួមប្រជុំពិភាក្សា ស្តីពីការរៀបចំឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ "ការអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន "កម្រិតបឋមសិក្សា និង ចាប់ពីកម្រិតបឋមសិក្សា និងមធ្យមសិក្សា លើសៀវភៅ "ការអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន "កម្រិតបឋមសិក្សា និង មធ្យមសិក្សា នៅសាលាគរុកោសល្យខេត្តកំពង់ចាមក្រោមអធិបតីលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលមានអ្នក ចូលរួមសរុប១៦នាក់ ស្រី០៣នាក់។

  ○ បានធ្វើការពិនិត្យ និងកែសម្រួលលើអក្ខរាវិរុទ្ធ រូបភាពលើសៀវភៅ "ការអប់រំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" កម្រិត បឋមសិក្សា និងមធ្យមសិក្សា ដែលក្រសួងអប់រំ យុវជន និងកីឡា បានផ្ញើមកដើម្បីជួយពិនិត្យ មុននឹងធ្វើការបោះពុម្ព។

  ○ បានអញ្ជើញចូលរួមកិច្ចប្រជុំ កែសម្រួលទៅលើសេចក្តីព្រាង "គោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍" ចំនួន០២លើក មានអ្នកចូលរួម ១៥ នាក់ ស្រី០៣នាក់ នៅសាលប្រជុំគ.ជ.ប.ជ។

  ○ បានអញ្ជើញចូលរួមប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ជាមួយថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការជាតិ អន្តរជាតិ ក្រោមប្រធានបទស្តីពី Ship and Shore's Right នៅសាលប្រជុំគ.ជ.ប.ជ។

  ○ បានអញ្ជើញចូលរួមប្រជុំពិភាក្សារៀបចំសមាសភាពក្រុមការងារ និងឯកសារសម្រាប់វគ្គបណ្តុះបណ្តាល "សៀវភៅអប់រំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និង លំនាំនៃការបង្រៀន" ជាមួយនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំយុវជន និងកីឡា អ្នកចូលរួម ១២នាក់ ស្រី០១នាក់។

- លោកឧត្តមសេនីយ៍ទោ **រ៉ន សុភ័ក្ត្រវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការស្វែងយល់ និងការរាយការណ៍ពី ការរំលោភបំពានផ្លូវភេទលើកុមារ ដែលរៀបចំដោយអង្គការជំហានដំបូងកម្ពុជា មានអ្នកចូលរួមសរុប៤៣នាក់ ស្រី១៧នាក់ នៅសាលប្រជុំគ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**

- លោកឧត្តមសេនីយ៍ទោ **សេក ស៊ីវ៉េត** ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួម និងសហការជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ចុះស្វែងយល់ពីបច្ចុប្បន្នភាព ក្នុងការបញ្ជូនពលករត្រឡប់មកវិញ និងការគ្រប់គ្រងពលករដែលតម្រូវអោយធ្វើចត្តាឡីស័ក ចំណុចប្រឈមផ្សេងៗ ដើម្បីរួមគ្នាដោះស្រាយ នៅតាមបណ្តាច្រក នៃខេត្តជាប់ព្រំដែន(ឧត្តរមានជ័យ បាត់ដំបង ប៉ៃលិន) ក្រោមការដឹកនាំរបស់ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- លោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួម និងអមដំណើរលោកជំទាវ អគ្គលេខាធិការ ចុះចែកសម្ភារៈមានដូចជា អាល់កុល ម៉ាស់ ជូនបុគ្គលិក សុខាភិបាល និងបានជួបសំណេះសំណាល ជាមួយពលករ ចំនួន ៥០រូប ដែលទើបបានបញ្ជូនត្រឡប់មកពីប្រទេសថៃ នៅមណ្ឌលសំចត ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**

- ឯកឧត្តម អគ្គលេខាធិការរង៖
  - បានចូលរួមកិច្ចប្រជុំ ឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ ជាមួយអន្តរក្រសួង ស្ថាប័ន ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃអគារ S ។
  - បានចូលរួមកិច្ចប្រជុំប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន(SOMTC) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំក្រសួងមហាផ្ទៃ។
  - បានចូលរួមកិច្ចប្រជុំ ក្រុមការងារបច្ចេកកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT កម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**

- លោកប្រធានក្រុមជំនួយកិច្ចការ៖
  - បានចូលរួមប្រជុំក្នុងពិធី ប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន ( SOMTC ) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និង ជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំ "S"តូច ទីស្តីការក្រសួងមហាផ្ទៃ។
  - បានចូលរួមពិនិត្យកែសម្រួលសេចក្តីព្រៀងគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។
  - បានចូលរួមពិនិត្យកែសម្រួលខ្លឹមសារ "MOU "ជាភាសាអង់គ្លេស របស់អង្គការ A 21 Foundation បញ្ចប់ មុននឹងដាក់ជូន **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះហត្ថលេខា និងបោះត្រាមួយច្បាប់ទៀត ក្រោមការសម្របសម្រួលដោយ **លោកជំទាវ** ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គជ.ប.ជ.។
  - បានចូលរួមពិនិត្យកែសម្រួល និងផ្ទៀងផ្ទាត់ខ្លឹមសារ SOP រវាងភាសាខ្មែរ និងអង់គ្លេស តាមការចង្អុលបង្ហាញពី ឯកឧត្តម **ឡាំ ជា** មុននឹងដាក់ជូន សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ ជ.ប.ជ. ពិនិត្យ និងស្នើសុំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ផ្តល់សិទ្ធិប្រទានជូន លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ចុះហត្ថលេខាជំនួស។
  - បានចូលរួមជាតំណាង **លោកជំទាវ** ឧត្តមសេនីយ៍ឯកអគ្គលេខាធិការ គ.ជ.ប.ជ ក្រុមការងារបច្ចេកទេសកម្មវិធី អាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា(ASEAN-ACT) ស្តីពីវឌ្ឍនភាពដែលកម្មវិធីនេះ សម្រេចបានក្នុងឆ្នាំ ២០២០ និងសេចក្តីព្រាងផែនការការងារឆ្នាំ ២០២១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN- ACT កម្ពុជា នៅសណ្ឋាគារ កាំបូឌីយ៉ាណា។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ អគ្គលេខាធិការរង៖<br>○ តំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** អមដំណើរដោយ ឯកឧត្តមអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមបើកសិក្ខាសាលាឆ្លុះបញ្ចាំង លទ្ធផលការងារប្រចាំឆ្នាំ នៃគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព គម្រោងប្រចាំឆ្នាំរបស់អង្គការឃែរ សហការជាមួយ គ ជ.ប.ខ.នៅខេត្តកំពង់ស្ពឺ អ្នកចូលរួមសរុបចំនួន ៥០នាក់ ស្រី ៣៥នាក់។<br>○ តំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ អមដំណើរដោយ ឯកឧត្តមអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ របស់អង្គការឃែរ ដែលបានសហការជាមួយ គ.ខ.ប.ជ ខេត្តព្រះសីហនុ ក្រោមការគាំទ្រពីមូលនិធិ UNWOMEN និងសហភាពអឺរ៉ុប អ្នកចូលរួមសរុបចំនួន៤៥នាក់ ស្រី៣២នាក់។<br>○ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គ "គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច អាណត្តិទី២ លើកទី១ ឆ្នាំ២០២១" ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដឹកនាំកិច្ចប្រជុំ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**<br>- បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ គម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព និងធ្វើជាវាគ្មិន ក្រោមការដឹកនាំរបស់លោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង នៅសាលាខេត្តកំពង់ស្ពឺ ក្រោមការឧបត្ថម្ភគាំទ្រដោយអង្គការឃែរអន្តរជាតិ ប្រចាំកម្ពុជា។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ក្រោមការឧបត្ថមគាំទ្រមូលនីធិ UN-WOMEN អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ CWCC នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។<br>- បានបូកសរុបទិន្នន័យពលករកម្ពុជា ដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេស ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ប្រចាំថ្ងៃទាំង២៥ ខេត្តរាជធានី ជូនថ្នាក់ដឹកនាំគ.ជ.ប.ជ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - ចូលរួមកិច្ចប្រជុំជាមួយ គ.ជ.ប.ជ ចំនួន ០៣លើក៖ ១.កិច្ចប្រជុំឆ្លងបាយការណ៍ឆ្នាំ២០២០។ ២-៣. កិច្ចប្រជុំត្រៀម និងកិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ ស្តីពី ស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់។<br>- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ដែលរៀបចំដោយក្រសួងយុត្តិធម៌ និងASEAN-ACT ចំនួន០១លើក។<br>- ចូលរួមសិក្ខាសាលាស្តីពី ទេសន្តរប្រវេសន៍ ដែលរៀបចំដោយ គ.ជ.ប.ជ និងអង្គការ នៅភ្នំពេញ ០១លើក។<br>- វគ្គបណ្តុះបណ្តាលចំនួន០៣លើក៖ ១.គ្រូបង្គោលស្តីពី ផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC ។ ២.ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការតំណក់ទឹកប៉ោយប៉ែត(មណ្ឌលសំចតប៉ោយប៉ែត)។ ៣.ស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីគ្រប់គ្រងការវិលត្រឡប់មកវិញនៃជនទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៦លើក អ្នកចូលរួមសរុបចំនួន ៤៤៨នាក់ (ស្រី ២៤៦នាក់) | |
|---|---|
| ខេត្តកណ្ដាល | - ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែធ្នូ ចំនួន០១លើក អ្នកចូលរួមចំនួន ៤០នាក់ ស្រី២១នាក់។<br>- ក្រុមការងារក្រុង-ស្រុក ប្រជុំពង្រឹងតួនាទី ភារកិច្ច ចំនួន០៧លើក អ្នកចូលរួមចំនួន ១៨២នាក់ ស្រី១១១នាក់។<br>- បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ |
| ខេត្តសៀមរាប | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែ ចំនួន ០២លើក អ្នកចូលរួមចំនួន ៧១នាក់ ស្រី៤១នាក់។<br>- គ.ខ.ប.ជ ថ្នាក់ក្រុង-ស្រុក ប្រជុំប្រចាំខែ ចំនួន ០៥លើក អ្នកចូលរួមចំនួន ១២៤នាក់ ស្រី៣៥នាក់។<br>- បានអមដំណើរលោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អង្គការ UNFPA, UNICEF, WHO និងអង្គការ IOM ចុះពិនិត្យ និងវាយតម្លៃបញ្ចប់គម្រោងលើកកម្ពស់ជីវភាពពលករចំណាកស្រុកពីក្រៅប្រទេស ចំនួន០១លើក នៅស្រុកសូទ្រនិគម ស្រុកក្រឡាញ់ និងស្រុកពួក ខេត្តសៀមរាប។ |
| ខេត្តព្រៃវែង | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ |
| ខេត្តកំពង់ចាម | - គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន ៣១នាក់ ស្រី២២នាក។ |
| ខេត្តកោះកុង | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត ប្រជុំក្រុមការងារថ្នាក់ក្រុង-ស្រុក ចំនួន០២លើក អ្នកចូលរួម ៥១នាក់ ស្រី១៦នាក់។<br>- បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ |
| ខេត្តកំពង់ស្ពឺ | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ |
| ខេត្តមណ្ឌលគិរី | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- មន្ទីរកិច្ចនារី បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី សកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច ០១លើក។ |